# សុន្ទរកថា

## លោក ផុន យុទ្ធ សក្ការា

## តំណាងអង្គការសង្គមស៊ីវិលធ្វើការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍

## ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ លើកទី ១៨

## នៅសាលសន្និសីទចតុមុខ ថ្ងៃទី ០១ ធ្នូ ២០១០

## "ខ្ញុំសន្យា! រួមគ្នាទប់ស្កាត់ជំងឺអេដស៍"

- សូមគោរព លោកជំទាវបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចំពោះការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរពឯកឧត្តមវេជ្ជ. **នុត សុខុម** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោក ជំទាវ ភ្ញៀវជាតិ អន្តរជាតិ លោក លោកស្រីតំណាងម្ចាស់មូលនិធិ ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការជាតិ និងអន្តរជាតិជាទីគោរព
- បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ ដែលមានវត្តមាននៅទីនេះជាទីស្រឡាញ់រាប់អាន !

ក្នុងនាមតំណាងឱ្យអង្គការសង្គមស៊ីវិល ដែលកំពុងតែអនុវត្តន៍កម្មវិធីអេដស៍នៅប្រទេសកម្ពុជា ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាគណៈអធិបតីក្នុងពិធីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍លើកទី ១៨ នេះ។ ថ្ងៃនេះជាថ្ងៃដ៏វិសេសវិសាលខ្លាំងណាស់ដែលយើង ទាំងអស់គ្នាបានប្រារព្ធពិធីនេះឡើង ហើយដែលការប្រារព្ធពិធីនេះ មានន័យថារាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធទាំងអស់កំពុងយកចិត្ត ទុកដាក់យ៉ាងខ្លាំងទៅលើការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ រយៈពេលកន្លងមកនេះអង្គការ សង្គមស៊ីវិល បានចូលរួមជាដៃគូសហការណ៍យ៉ាងសស្រាក់សស្រាំ និងស្អិតរមួតជាមួយរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជា ។

**លោកជំទាវបណ្ឌិតជាទីគោរព!**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្អូនៗ និងក្មួយៗ ទាំងអស់ជាទីគោរព និងជាទីរាប់អាន!**

ថ្មីៗនេះប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ចំពោះវឌ្ឍនភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងបានអង្គការសហប្រជាជាតិប្រគល់ពានរង្វាន់គោលដៅសហសវត្សសម្រាប់ភាពជាអ្នកដឹកនាំល្អរបស់ជាតិ ការប្ដេជ្ញាខ្ពស់ និងវឌ្ឍនភាពឆ្ពោះទៅសម្រេចបាននូវគោលដៅសហសវត្សទី៦ ។ ហើយភាពជោគជ័យទាំងនោះបានដោយមានការចូលរួមយ៉ាងសកម្មពីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អ្នកដែលទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ដៃគូអភិវឌ្ឍន៍ព្រមទាំងម្ចាស់ជំនួយផងដែរ ។

ទន្ទឹមនឹងភាពជោគជ័យទាំងអស់នេះ យើងក៏ពុំទាន់បានបំពេញឱ្យបានគ្រប់ជ្រុងជ្រោយ នូវការសន្យារបស់យើងដែលបានសន្យាកន្លងមកក្នុងការឆ្លើយតបជាមួយក្រុមដែលប្រឈមមុខខ្ពស់ដូចជាៈ កុមារកំព្រា និងកុមារដែលងាយរងគ្រោះ អ្នកប្រើប្រាស់គ្រឿងញៀន បុរសស្រឡាញ់បុរស បុគ្គលិកបំរើសេវាតាមគ្រឹះស្ថានកម្សាន្តសប្បាយ អ្នកជំងឺអេដស៍ និងក្រុមយុវជនទាំងក្នុង និងក្រៅសាលា។

ក្នុងនាមអង្គការសង្គមស៊ីវិលដែលកំពុងបំពេញការងារប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមធ្វើការសំណូមពរយ៉ាងទទូចដល់ដៃគូអភិវឌ្ឍន៍ និងម្ចាស់មូលនិធិទាំងអស់ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាបង្កើនការប្ដេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសរកយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការគៀងគរប្រភពធនធានពីសហគមន៍ជាតិ និងអន្តរជាតិ និងធ្វើការពង្រឹងការដឹកនាំពីគ្រប់ស្ថាប័នដែលជាប់ពាក់ពន្ធ័ទាំងអស់ ដើម្បីធានានូវការឆ្លើយតបដោយប្រសិទ្ធិភាព និរន្តរភាព និងចំទិសដៅដែលជាអាទិភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នៅប្រទេសកម្ពុជា។ ខាងក្រោមនេះ ជាសំណូមពរមួយចំនួនដែលអង្គការសង្គមស៊ីវិល សូមលើកឡើងដើម្បីធ្វើការពិចារណា ក្នុងបទអន្តរាគមន៍ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជាៈ

- *ទី១: បង្កើន និងលើកកំពស់កិច្ចអន្តរាគមន៍បង្ការចំពោះក្រុមដែលងាយរងគ្រោះ*
- *ទី២: ការលើកកំពស់ការអប់រំពីយេនឌ័រ និងយន្តការការពារមេរោគអេដស៍ ដែលផ្ដល់សិទ្ធិជាម្ចាស់ដល់ស្ត្រីដើម្បីការពារខ្លួនជៀសផុតពីការឆ្លងមេរោគអេដស៍*

- *ទី៣: បន្តពង្រឹង និងពង្រីកកម្មវិធីថែទាំ និងគាំទ្រដល់អ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ដោយធានាឱ្យបានថា អ្នករស់នៅជាមួយមេរោគអេដស៍នៅតំបន់ជនបទដាច់ស្រយាល បានទទួលនូវសេវាថែទាំសុខភាពប្រកបដោយគុណភាព និងមានសុវត្ថិភាពស្បៀងអាហារ*
- *ទី៤: ធ្វើការលុបបំបាត់ការមាក់ងាយ និងការរើសអើងដែលរាំងស្ទះដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះមេរោគអេដស៍ដោយធ្វើការអនុវត្តន៍ និងកែប្រែគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗ*
- *ទី ៥: បង្កើនឆន្ទៈនយោបាយដែលគាំទ្រ និងការពារសិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងជនដែលងាយរងគ្រោះខ្ពស់បំផុត*
- *ទី ៦: លើកកម្ពស់ឱ្យមានការចូលរួមយ៉ាងសកម្មពីអង្គការសង្គមស៊ីវិល អ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងក្រុមដែលងាយរងគ្រោះបំផុតក្នុងការបង្កើតច្បាប់គោលនយោបាយនានាដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយប្រសិទ្ធិភាព*
- *ទី ៧: បន្តពង្រឹង និងពង្រីកកម្មវិធីបង្ការប្រកបដោយសុវត្ថិភាពចំពោះក្រុមអ្នកប្រឈមមុខខ្ពស់ ដើម្បីឱ្យពួកគេមានលទ្ធភាពទទួលយកសេវាកម្មដោយមិនមានការភ័យខ្លាច និងការរើសអើង*
- *ទី ៨: ជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជនក្នុងការឆ្លើយតបទៅនឹងការងារអេដស៍ និង*
- *ទី ៩: បង្កើនប្រភពធនធាន និងយន្តការគៀងគររកជំនួយជាមួយដៃគូ និងស្ថាប័នដែលជាប់ពាក់ព័ន្ធទាំងអស់ដើម្បីធានាឱ្យបាននូវប្រភពធនធានគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធិភាព*

គណៈកម្មាធិការសំរបសំរួលប្រយុទ្ធនឹងជំងឺអេដស៍ សូមធ្វើការប្តេជ្ញាចិត្តចូលរួមជាមួយស្ថាប័នពាក់ពន្ធ័ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ក្នុងការឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ជាពិសេសជួយបំពេញ បន្ថែមនូវភាពចន្លោះខ្វះខាតរបស់រាជ រដ្ឋាភិបាលតាមរយៈការចូលរួមក្នុងការរៀបចំផែនការ ការអនុវត្តការតាមដាន ការកសាងសមត្ថភាព និងការពង្រឹងយន្តការដែលមានស្រាប់ ដើម្បីធានាឱ្យបាននូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

ជាទីបញ្ចប់ខ្ញុំបាទសូមគោរពជូនពរ លោកជំទាវបណ្ឌិត ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗទាំងអស់ នៃអង្គពិធីទាំងមូល សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងប្តេជ្ញារួមគ្នាសម្រេចឱ្យបាននូវការប្រយុទ្ធ និងឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា។

**សូមអរគុណ!**